# សេចក្តីពន្យល់គតិយុត្តិ

សម្រាប់ខែកុម្ភៈ (លេខ ៦)

- **ការចុះបញ្ជីពន្ធដារ និងការធ្វើបច្ចុប្បន្នភាពព័ត៌មានសម្រាប់សហគ្រាសដែលបានចុះបញ្ជី**

***ឯកសារយោង:***

១.ព្រះរាជក្រមលេខ *នស/រកម/០២៩៧/០៣ ចុះថ្ងៃទី ២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧* ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីសារពើពន្ធ។

២.ក្រឹត្យច្បាប់ស្តីពីពន្ធប៉ាតង់ចុះថ្ងៃទី ១៤ ខែមីនា ឆ្នាំ១៩៨៥

៣.ប្រកាសលេខ ១១៣៩ សហវ.ប្រក ចុះថ្ងៃទី ០៩ ខែតុលា ឆ្នាំ២០១៤ ស្តីពីការចុះបញ្ជីពន្ធដារ

# ការចុះបញ្ជីពន្ធដារ និងការធ្វើបច្ចុប្បន្នភាពព័ត៌មាន
# សម្រាប់សហគ្រាសដែលបានចុះបញ្ជី

## <u>កថាខណ្ឌទី១៖ ការចុះបញ្ជីពន្ធដារ</u>

### ១.តើអ្វីទៅជាការចុះបញ្ជីពន្ធដារ?

ការចុះបញ្ជីពន្ធដារ សំដៅដល់ការចុះបញ្ជីតាម**របបស្វ័យប្រកាស** និងរបបម៉ៅការ នៅរដ្ឋបាលសារពើពន្ធចំពោះបុគ្គលទាំងឡាយណាដែលមាន**សកម្មភាពសេដ្ឋកិច្ច**នៅព្រះរាជាណាចក្រកម្ពុជា។*(ប្រការ ៤ នៃប្រកាសស្តីពីការចុះបញ្ជីពន្ធដារ)*

### ២.តើបុគ្គលប្រភេទណាត្រូវចុះបញ្ជីតាមរបបស្វ័យប្រកាស?

បុគ្គលដែលត្រូវចុះបញ្ជីតាម របបស្វ័យប្រកាស គឺសំដៅទៅលើបុគ្គលដែលមានស្ថានភាពផលរបរប្រចាំឆ្នាំចាប់ពី៖

- ៥០០លានរៀល សម្រាប់ការផ្គត់ផ្គង់ទំនិញ
- ២៥០ លានរៀល សម្រាប់ការផ្គត់ផ្គង់សេវា និង
- ១២៥លានរៀលសម្រាប់កិច្ចសន្យាជាមួយរដ្ឋាភិបាល

ក្រៅពីចំណុចទាំង ៣ ខាងលើនេះក្រុមហ៊ុនដែលចុះបញ្ជីស្ម័គ្រចិត្តក្នុងរបបស្វ័យប្រកាស និងក្រុមហ៊ុនដែលអនុញ្ញាតិដោយក្រុមប្រឹក្សាអភិវឌ្ឍកម្ពុជា ជាគម្រោងវិនិយោគដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ក៏ត្រូវចាត់ទុកថាស្ថិតក្រោមរបបស្វ័យប្រកាសផងដែរ ហើយមានកាតព្វកិច្ចក្នុងការចុះបញ្ជីពន្ធដារ។ **រោងចក្រផ្នែកវាយនភ័ណ្ឌ កាត់ដេរ និងផលិតស្បែកជើងដែលបម្រើសម្រាប់ការនាំចេញទាំងអស់គឺស្ថិតក្រោមរបបស្វ័យប្រកាស ដែលមានកាតព្វកិច្ចក្នុងការចុះបញ្ជីពន្ធដារ។**

### ៣.អ្វីទៅជាសកម្មភាពសេដ្ឋកិច្ច?

សកម្មភាពសេដ្ឋកិច្ចសំដៅទៅលើសកម្មភាពរបស់បុគ្គលដែលធ្វើអាជីវកម្ម ឬសកម្មភាព ជានិច្ចជាកាលជាប់បន្ត ឬមួយដងមួយគ្រា ដើម្បីរក ឬមិនរកចំនេញ ក្នុងការផ្គត់ផ្គង់ ឬមានបំណងផ្គត់ផ្គង់ទំនិញ ឬសេវាដល់បុគ្គលដទៃក្នុងគោលដៅដើម្បីបានអត្ថប្រយោជន៍អ្វីមួយ។ *(ប្រការ ៤ នៃប្រកាសស្តីពីការចុះបញ្ជីពន្ធដារ)*

### ៤.តើសហគ្រាសត្រូវចុះបញ្ជីនៅឯណា និងនៅពេលណា?

សហគ្រាសនីតិបុគ្គល ឬក្រុមអាជីវកម្ម ឬសហគ្រាសឯកបុគ្គល ឬបុគ្គលទាំងឡាយត្រូវទៅចុះបញ្ជីនៅរដ្ឋបាលសារពើពន្ធ(នាយកដ្ឋានអ្នកជាប់ពន្ធធំ) ក្នុងរយៈពេល១៥ថ្ងៃ នៃថ្ងៃធ្វើការ ក្រោយពីចាប់ផ្តើមធ្វើសកម្មភាពសេដ្ឋកិច្ច ឬក្រោយពីពេលទទួលបានការចុះបញ្ជីនៅក្រសួងពាណិជ្ជកម្ម ឬក្រសួងស្ថាប័នពាក់ព័ន្ធ។

### ៥.តើការចុះបញ្ជីពន្ធដារ និងការធ្វើបច្ចុប្បន្នភាពព័ត៌មានតាមប្រព័ន្ធថ្មីត្រូវធ្វើឡើងក្នុងគោលបំណងអ្វី?

ការចុះបញ្ជីពន្ធដារ និងការធ្វើបច្ចុប្បន្នភាពព័ត៌មានតាមប្រព័ន្ធថ្មីនេះ ត្រូវបានធ្វើឡើងក្នុងគោលបំណងដើម្បីពង្រឹង និងបង្កើនប្រសិទ្ធិភាពនៃការចុះបញ្ជីពន្ធដារ ដើម្បីគ្រប់គ្រងទិន្នន័យសហគ្រាសនីតិបុគ្គល ពង្រឹងការផ្តល់សេវាជូនដល់អ្នកជាប់ពន្ធឲ្យកាន់តែមានលក្ខណៈល្អប្រសើរ និងពង្រឹងការគាំទ្រដល់ការគ្រប់គ្រងការដាក់លិខិតប្រកាស ការធ្វើសវនកម្ម និងការប្រមូលបំណុលពន្ធ ឲ្យកាន់តែប្រសើរមានតម្លាភាព និងប្រសិទ្ធិភាព។

### ៦.តើសហគ្រាស ឬរោងចក្រដែលត្រូវមកចុះបញ្ជីពន្ធដារ ត្រូវធ្វើដូចម្តេច?

ដោយមានការកែប្រែប្រព័ន្ធនៃការចុះបញ្ជីពន្ធដារ សម្រាប់សហគ្រាសនីតិបុគ្គល ឬក្រុមអាជីវកម្ម ឬសហគ្រាសឯកបុគ្គលថ្មីទាំងឡាយ ដែលមិនទាន់ដំណើរការសកម្មភាពសេដ្ឋកិច្ច ឬចាប់ផ្តើមសកម្មភាពសេដ្ឋកិច្ចដែលតិចជាង ១៥ថ្ងៃ នៃថ្ងៃធ្វើការ ហើយដែលមានកាតព្វកិច្ចចុះបញ្ជីពន្ធដារ ត្រូវ**ស្នើសុំចុះបញ្ជីដោយផ្ទាល់**នៅរដ្ឋបាលសារពើពន្ធ *(នាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធធំ- ការិយាល័យសេវាអ្នកជាប់ពន្ធ និងចុះបញ្ជី)* ឬចុះតាមប្រព័ន្ធអេឡិចត្រូនិច តាមរយៈគេហទំព័រ https://cambodia.tax.gov.kh/reg/?page=business_register/register ។

### ៧.តើសហគ្រាស ឬរោងចក្រដែលត្រូវចុះបញ្ជីពន្ធដារ តាមរបបស្វ័យប្រកាសត្រូវបំពេញលក្ខខណ្ឌអ្វីខ្លះ?

បើរោងចក្រ ឬសហគ្រាសដែលត្រូវចុះបញ្ជីពន្ធដារតាមរបបស្វ័យប្រកាសត្រូវបំពេញលក្ខខណ្ឌដូចជា៖

#### ក.លក្ខខណ្ឌបុគ្គល

ប្រធានក្រុមប្រឹក្សាភិបាល ឬម្ចាស់សហគ្រាស ឬប្រធានអង្គការ ត្រូវមកថតរូបស្កេនម្រាមដៃផ្ទាល់នៅរដ្ឋបាលសារពើពន្ធ *(នាយកដ្ឋានអ្នកជាប់ពន្ធធំ - ការិយាល័យសេវាអ្នកជាប់ពន្ធ និងចុះបញ្ជី)* និងត្រូវបំពេញព័ត៌មានក្នុងទម្រង់ដែលបានកំណត់ដោយរដ្ឋបាលសារពើពន្ធ ហើយភ្ជាប់ជាមួយឯកសារមួយចំនួន។

#### ខ.លក្ខខណ្ឌសំណុំឯកសារ

ដើម្បីកាត់បន្ថយ ឬរង់ចាំច្បាប់ថតចម្លងដែលមានបញ្ជាក់ពីក្រសួងស្ថាប័នសាមី ឬមានសមត្ថកិច្ច អគ្គនាយកដ្ឋានពន្ធដារ ការិយាល័យសេវាអ្នកជាប់ពន្ធ និងចុះបញ្ជីពន្ធដារ ក៏ទទួលយកឯកសារថតចម្លងផងដែរ ប៉ុន្តែអ្នកចុះបញ្ជីត្រូវភ្ជាប់ជាមួយឯកសារច្បាប់ដើមសម្រាប់មន្ត្រីចុះបញ្ជីបញ្ជាក់ថាបានថតចម្លងចេញពីច្បាប់ដើម។ ឯកសារទាំងនោះរួមមាន៖

សម្រាប់រោងចក្រ សហគ្រាសនីតិបុគ្គល សហគ្រាសឯកបុគ្គល

- លិខិតបញ្ជាក់ការចុះបញ្ជីនៃក្រសួងពាណិជ្ជកម្ម ឬក្រសួង ស្ថាប័នពាក់ព័ន្ធ
- លក្ខន្តិកៈក្រុមហ៊ុនរោងចក្រ សម្រាប់នីតិបុគ្គល
- លក្ខន្តិកៈបញ្ជាក់ការតម្កល់ដើមទុនចុះបញ្ជីនៅធនាគារ ឬ Bank Statement ឬ Bank Registration ដែលមាន Account Name និង Account Number។

ឯកសារបញ្ជាក់អត្តសញ្ញាណរបស់ប្រធានក្រុមប្រឹក្សាភិបាល អភិបាល កម្មសិទ្ធិករ ឬម្ចាស់ភាគហ៊ុន និងបណ្ណាធិការ៖

- អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬលិខិតឆ្លងដែន

- សៀវភៅគ្រួសារ ឬប័ណ្ណស្នាក់នៅ ឬលិខិតបញ្ជាក់ការស្នាក់នៅដែលចេញដោយអាជ្ញាធរមានសមត្ថកិច្ច *(សម្រាប់បុគ្គលខាងលើដែលមិនស្នាក់នៅកម្ពុជា អាចធ្វើលិខិតបញ្ជាក់ទីលំនៅដោយមានការបញ្ជាក់ជាផ្លូវការពីមេធាវី ឬសារការីពីទីតាំងក្រុមហ៊ុន ឬកន្លែងដែលបុគ្គលនោះស្នាក់នៅ)*
- រូបថតបច្ចុប្បន្នមិនលើសពីរយៈពេល ៣ខែ ដែលមានទំហំ ៣៥* ៤៥មីលីម៉ែត្រចំនួន ១សន្លឹក របស់អភិបាល ម្ចាស់ភាគហ៊ុន បណ្ណាធិការ អ្នកតំណាង ដែលមានការបញ្ជាក់ឈ្មោះម្ចាស់រូបថត និងចុះហត្ថលេខាទទួលខុសត្រូវដោយប្រធានក្រុមប្រឹក្សាភិបាល។

សម្រាប់ឯកសារបញ្ជាក់ទីតាំងចាត់ការសហគ្រាស អាជីវកម្មគោលដើម សាខាសហគ្រាស និងឃ្លាំង

- ប័ណ្ណកម្មសិទ្ធិកាន់កាប់ទីតាំង (បើទីតាំងជាទ្រព្យរបស់ក្រុមហ៊ុនរោងចក្រ) ឬកិច្ចសន្យាជួលទីតាំងប្រកបអាជីវកម្ម ធ្វើសកម្មភាពសេដ្ឋកិច្ច
- លិខិតបញ្ជាក់ការបង់ពន្ធអចលនវត្ថុ ឬព័ត៌មានអចលនទ្រព្យ

ឯកសារផ្សេងៗ

- វិញ្ញាបនប័ត្រចុះបញ្ជីរបស់គណៈកម្មាធិការវិនិយោគកម្ពុជា ឬគណៈកម្មាធិការតំបន់សេដ្ឋកិច្ចពិសេសនៃក្រុមប្រឹក្សាអភិវឌ្ឍកម្ពុជា ឬអនុគណៈកម្មាធិការវិនិយោគរាជធានី-ខេត្ត (សម្រាប់គម្រោងវិនិយោគដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់)។
- អាជ្ញាប័ណ្ណដែលចេញដោយក្រសួង ស្ថាប័ន មានសមត្ថកិច្ច(បើមាន)។

**៨.បើបំពេញលក្ខខណ្ឌខាងលើរួចរាល់ហើយ តើត្រូវចំណាយរយៈពេលប៉ុន្មានសម្រាប់ទទួលបានវិញ្ញាបនប័ត្រចុះបញ្ជី?**

- ចំពោះការចុះបញ្ជីនៅរដ្ឋបាលសារពើពន្ធ (ការិយាល័យសេវាអ្នកជាប់ពន្ធ និងចុះបញ្ជី) តាមរយៈការបំពេញពាក្យស្នើសុំចុះបញ្ជីពន្ធដារអាចនឹងចំណាយរយៈពេល ពី៧ថ្ងៃទៅ ១០ថ្ងៃ នៃថ្ងៃធ្វើការ ក្នុងការចេញវិញ្ញាបនប័ត្រចុះបញ្ជីពន្ធដារ និងប័ណ្ណសម្គាល់ការចុះបញ្ជីពន្ធដារ ដោយរដ្ឋបាលសារពើពន្ធ សម្រាប់ផ្តល់ភាពងាយស្រួលក្នុងការបំពេញកាតព្វកិច្ចសារពើពន្ធ។
- ចំពោះការចុះបញ្ជីតាមរយៈប្រព័ន្ធអេឡិកត្រូនិកE-Registration តាមរយៈគេហទំព័ររបស់អគ្គនាយកដ្ឋានពន្ធដារ (https://cambodia.tax.gov.kh/reg/?page=business_register/register )អាចនឹងចំណាយរយៈពេលពី ១ថ្ងៃ ទៅ៧ថ្ងៃ នៃថ្ងៃធ្វើការក្នុងការចេញវិញ្ញាបនប័ត្រចុះបញ្ជីពន្ធដារ និងប័ណ្ណសម្គាល់ការចុះបញ្ជីពន្ធដារ ដោយរដ្ឋបាលសារពើពន្ធ។

  **សំគាល់:** ទោះជាត្រូវចុះបញ្ជីតាមប្រព័ន្ធអេឡិកត្រូនិក E-Registration ក៏ដោយក៏ប្រធានក្រុមប្រឹក្សាភិបាល ឬម្ចាស់សហគ្រាស ឬប្រធានអង្គការ ត្រូវមកថតរូបស្កេនម្រាមដៃផ្ទាល់នៅរដ្ឋបាលសារពើពន្ធ *(នាយកដ្ឋានអ្នកជាប់ពន្ធធំ - ការិយាល័យសេវាអ្នកជាប់ពន្ធ និងចុះបញ្ជី)*ផងដែល។

**៩.តើរោងចក្រសហគ្រាសដែលត្រូវចុះបញ្ជីពន្ធដារតាមរបបស្វ័យប្រកាសត្រូវបង់ថ្លៃសេវាចុះបញ្ជីចំនួនប៉ុន្មាន?**

សម្រាប់រោងចក្រសហគ្រាសដែលមានកាតព្វកិច្ចចុះបញ្ជីពន្ធដារនៅរដ្ឋបាលសារពើពន្ធត្រូវបង់ថ្លៃសេវាចុះបញ្ជី ចេញវិញ្ញាបនបត្រចុះបញ្ជីពន្ធដារ និងប័ណ្ណសម្គាល់ការចុះបញ្ជីពន្ធដារ ក្នុងតម្លៃ ៤០០.០០០រៀល (បួនសែនរៀល)។

**១០.បើរោងចក្រសហគ្រាសមិនបានអនុវត្តកាតព្វកិច្ចចុះបញ្ជីនៅរដ្ឋបាលសារពើពន្ធ តើត្រូវទទួលខុសត្រូវយ៉ាងដូចម្តេច?**

ចំពោះរោងចក្រសហគ្រាសដែលមិនបានអនុវត្តកាតព្វកិច្ចចុះបញ្ជីនៅរដ្ឋបាលសារពើពន្ធ ត្រូវចាត់ទុកថាជាអំពើរាំងស្ទះការអនុវត្តបទប្បញ្ញត្តិស្តីពីពន្ធដារ (មាត្រា១២៨ច្បាប់ស្តីពីសារពើពន្ធ)។ ការរាំងស្ទះការអនុវត្តបទប្បញ្ញត្តិស្តីពីពន្ធដារ ពន្ធបន្ថែមត្រូវកំណត់ ២.០០០.០០០លានរៀលចំពោះអ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស។

**កថាខណ្ឌទី២៖ការធ្វើបច្ចុប្បន្នភាពព័ត៌មានរបស់សហគ្រាសដែលបានចុះបញ្ជី**

**១.តើរោងចក្រសហគ្រាសប្រភេទណាដែលត្រូវធ្វើបច្ចុប្បន្នភាព?**

ចំពោះរោងចក្រសហគ្រាសគ្រឹះស្ថានដែលបានចុះបញ្ជីពន្ធដារមុនថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ២០១៤ ប្រធានក្រុមប្រឹក្សាភិបាល ឬម្ចាស់សហគ្រាសត្រូវមកធ្វើបច្ចុប្បន្នភាពព័ត៌មាន។ ការធ្វើបច្ចុប្បន្នភាពត្រូវធ្វើឡើងតាមការជូនដំណឹងរបស់រដ្ឋបាលសារពើពន្ធ ដើម្បីទទួលបានវិញ្ញាបនបត្រចុះបញ្ជីពន្ធដារថ្មី និងប័ណ្ណសម្គាល់ការចុះបញ្ជីពន្ធដារ។

**២.តើរោងចក្រសហគ្រាសតាមរបបស្វ័យប្រកាសដែលមានកាតព្វកិច្ចត្រូវធ្វើបច្ចុប្បន្នភាពព័ត៌មានត្រូវបង់ថ្លៃសេវាចំនួនប៉ុន្មាន?**

ការធ្វើបច្ចុប្បន្នភាពព័ត៌មានរបស់រោងចក្រសហគ្រាសតាមរបបស្វ័យប្រកាស ដែលបានចុះបញ្ជីពន្ធដារត្រូវបង់ថ្លៃសេវាចេញវិញ្ញាបនបត្រចុះបញ្ជីពន្ធដារថ្មី និងប័ណ្ណសម្គាល់ការចុះបញ្ជីពន្ធដារ នៅរដ្ឋបាលសារពើពន្ធក្នុងតម្លៃ ២០០.០០០ រៀល (ពីរសែនរៀល)។ ។

**សម្គាល់៖** រោងចក្រសហគ្រាសដែលបានចុះបញ្ជីមុនថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ២០១៤ ដែលមិនទាន់បានអញ្ជើញមកធ្វើបច្ចុប្បន្នភាពព័ត៌មាន អាចមកធ្វើការបង់ពន្ធប៉ាតង់ជាមុនសិន ដើម្បីទទួលបានវិក័យប័ត្របង់ប៉ាតង់។ ចំនែកឯប័ណ្ណប៉ាតង់នឹងផ្តល់ជូនក្រោយពេលធ្វើបច្ចុប្បន្នភាពជាមួយវិញ្ញាបនបត្រចុះបញ្ជីពន្ធដារថ្មី ជាមួយនឹងបណ្ណសម្គាល់ការចុះបញ្ជីពន្ធដារ។ ការបង់ពន្ធប៉ាតង់មិនត្រូវយឺតជាងថ្ងៃទី ៣០ខែមីនានៃឆ្នាំបង់ពន្ធនោះទេ។

តាក់តែងឡើងដោយៈ
<u>ក្រុមការងារផ្នែកច្បាប់ និងការងារ</u>
នៃសមាគមរោងចក្រកាត់ដេរនៅកម្ពុជា

**<u>សេចក្តីប្រកាសបដិសេធៈ</u>** សេចក្តីពន្យល់បកស្រាយគតិយុត្តិខាងលើនេះមានគោលបំណងគ្រាន់តែជាការផ្តល់ព័ត៌មានបន្ថែមដល់សមាជិកតែប៉ុណ្ណោះ និងមិនមែនជាការផ្តល់ដំបូន្មានផ្នែកច្បាប់ឡើយ។ សមាគមមិនទទួលខុសត្រូវចំពោះការខូចខាតនានាដែលកើតចេញពីការអនុវត្តន៍តាមសេចក្តីពន្យល់នេះឡើយ។ សមាគមសូមលើកទឹកចិត្តឲ្យសមាជិកស្វែងរកការពន្យល់បន្ថែមពីអ្នកឯកទេសខាងច្បាប់មុននឹងអនុវត្តតាមការបកស្រាយខាងលើនេះ។ សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងមកលេខាធិការដ្ឋានសមាគមតាមរយៈទូរស័ព្ទលេខ ០២៣ ៣០១ ១៨១ ឬ អ៊ីម៉ែលៈoudom@gmac-cambodia.org ។